ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ២៩៦៩ មស.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី១១

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ត្រាស់បង្គាប់ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ត្រាស់បង្គាប់ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ត្រាស់បង្គាប់ផ្ទេរសាលាភូមិន្ទរដ្ឋបាល ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/៤០/០៤៩៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.តក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្តីពីការលើកលែងលក្ខខណ្ឌអាយុ និងការកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល

- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល លេខ១៥៧ សករ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩

# សម្រេច

**ប្រការ១.-** អនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់លើកទី១១ ចំនួន ៩៥នាក់ (ជំនាញរដ្ឋបាលទូទៅ ៣៥នាក់ ជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៣៥នាក់ និងជំនាញទំនាក់ទំនងអន្តរជាតិ ២៥នាក់) នៅសាលាភូមិន្ទរដ្ឋបាល ដោយត្រូវធ្វើការជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងនិស្សិត។

**ប្រការ២.-** កាលបរិច្ឆេទប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៩។
បេក្ខជនត្រូវជ្រើសរើសជំនាញមួយ ក្នុងចំណោមជំនាញទាំងបី នៅពេលដាក់ពាក្យសុំប្រឡងប្រជែងសិស្ស មន្ត្រីជាន់ខ្ពស់លើកទី១១។

**ប្រការ៣.-** **បេក្ខជនត្រូវបំពេញលក្ខខណ្ឌសម្រាប់ការជ្រើសរើសដូចខាងក្រោម ៖**

**- កម្រិតសញ្ញាបត្រ៖**

. បេក្ខជនជាមន្ត្រីរាជការ ឬនិស្សិត ត្រូវមានសញ្ញាបត្រទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

**- លក្ខខណ្ឌអាយុ៖**

. បេក្ខជនជាមន្ត្រីរាជការនិង បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ

. បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០(សែសិប)ឆ្នាំ គិតមកដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩

. បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ (សាមសិបប្រាំ)ឆ្នាំ គិតមកដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩

**- លិខិតថ្កោលទោស៖** ត្រូវមានលិខិតថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ នៅក្រោយពេលប្រឡងជាប់ជាស្ថាពរ

**- លិខិតពិនិត្យសុខភាព៖** ត្រូវមានលិខិតពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារនៅក្រោយពេលប្រឡងជាប់ជាស្ថាពរ

បញ្ជីបេក្ខជនដែលអនុញ្ញាតឱ្យចូលធ្វើវិញ្ញាសាប្រឡងប្រជែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។

**ប្រការ៤.-** វិញ្ញាសាប្រឡងប្រជែងរួមមាន ៖ វិញ្ញាសាសរសេរ និងវិញ្ញាសាសួរផ្ទាល់មាត់។

**ក- វិញ្ញាសាសរសេរលើកទី១ មាន ៖**

| | | |
|---|---|---|
| ១- សំណួរពហុចម្លើយ | "រយៈពេល ២ម៉ោង" | មេគុណ ១ |
| ២- ភាសាបារាំង ឬអង់គ្លេស | "រយៈពេល ១ម៉ោង៣០នាទី" | មេគុណ ១ |

**មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី១តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមប្រឡងវិញ្ញាសាសរសេរលើកទី២ ។**

ខ- វិញ្ញាសាសរសេរលើកទី២ មាន ៖

| | | |
|---|---|---|
| ១- អធិប្បាយពាក់ព័ន្ធនឹងចំណេះដឹងទូទៅ | " រយៈពេល ៣ម៉ោង " | មេគុណ ៣ |
| ២- ដោះស្រាយបញ្ហាតាមករណីសិក្សា | " រយៈពេល ២ម៉ោង " | មេគុណ ១ |
| ៣- ជំនាញ | "រយៈពេល៣ម៉ោង " | មេគុណ ៣ |

បេក្ខជនត្រូវជ្រើសរើសវិញ្ញាសាជំនាញរបស់ខ្លួនដូចខាងក្រោម ៖

- សេដ្ឋកិច្ច-ហិរញ្ញវត្ថុ ( សម្រាប់ជំនាញ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ )
- រដ្ឋបាលសាធារណៈ (សម្រាប់ជំនាញ រដ្ឋបាលទូទៅ)
- នីតិអន្តរជាតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ( សម្រាប់ជំនាញ ទំនាក់ទំនងអន្តរជាតិ )

**មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី២តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមប្រឡងវិញ្ញាសាសួរផ្ទាល់មាត់។**

**គ- វិញ្ញាសាសួរផ្ទាល់មាត់៖**

ធ្វើមូលវិចារណ៍លើបុគ្គលិកលក្ខណៈ និងលើហេតុប្បទ្វេសរបស់បេក្ខជន ក្នុងពេលតែមួយសម្រាប់រយៈពេលពី «១៥នាទីទៅ៣០នាទី» មេគុណ៣

**ប្រការ៥.-** ក្រោយការប្រឡងប្រជែង ប្រធានគណៈមេប្រយោគត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាសាលា។ របាយការណ៍នេះ នឹងត្រូវបញ្ជូនទៅក្រសួងមុខងារសាធារណៈ។

**ប្រការ៦.-** - ការទទួលស្គាល់ជាសិស្សមន្ត្រីជាន់ខ្ពស់ សាលាភូមិន្ទរដ្ឋបាលត្រូវធ្វើដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។ ក្នុងកំឡុងពេលចូលរៀន សិស្សត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភ ប្រចាំខែតាមការកំណត់របស់រាជរដ្ឋាភិបាល។ បេក្ខជនជាមន្ត្រីរាជការ ដែលបានប្រឡងជាប់ជាស្ថាពរនៅសាលាភូមិន្ទរដ្ឋបាល ត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅមុខតំណែង ឬក្របខ័ណ្ឌ មុនពេលចូលរៀននៅសាលាភូមិន្ទរដ្ឋបាល ដោយរក្សាបៀវត្សមូលដ្ឋាននៅអង្គភាពដើម ។

- សិស្សមន្ត្រីជាន់ខ្ពស់ត្រូវទទួលការបណ្តុះបណ្តាលរយៈពេល ២ឆ្នាំ។

**ប្រការ៧.-** ក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល នាយកសាលាភូមិន្ទរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៚

ថ្ងៃព្រហស្បតិ៍ ១៨រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩

**ពេជ្រ ប៊ុនធិន**

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- សមាជិកក្រុមប្រឹក្សាសាលា
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
លេខ...៦០៣...ស.ភ.រ

# សេចក្តីជូនដំណឹង

អនុលោមតាមសេចក្តីសម្រេចលេខ ២៩៦៩ មស.សសរ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្សមន្រ្តីជាន់ខ្ពស់លើកទី១១ សាលាភូមិន្ទរដ្ឋបាល សូមជូនដំណឹងដល់ និស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់ជំនាញឡើងទៅ ព្រមទាំង និស្សិត ដែលនឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយជោគជ័យ ក្នុងឆ្នាំ២០១៩នេះ ក៏ដូចជាមន្ត្រីរាជការទាំងអស់ឱ្យបានជ្រាបថា សាលានឹងរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី១១ ចំនួន ៩៥នាក់ (ជំនាញរដ្ឋបាលទូទៅ ៣៥នាក់, ជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៣៥នាក់, ជំនាញទំនាក់ទំនងអន្តរជាតិ ២៥នាក់)។ បេក្ខជនត្រូវជ្រើសរើសជំនាញនិងភាសាបរទេសជាមុនក្នុងការដាក់ពាក្យ សម្រាប់ការបណ្តុះបណ្តាលឆ្នាំ២០២០-២០២១។

- លក្ខខណ្ឌនៃការជ្រើសរើស សូមអានសេចក្តីសម្រេចលេខ ២៩៦៩ មស.សសរ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- កាលបរិច្ឆេទបំពេញពាក្យតាម Online ចាប់ផ្តើមពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ តទៅ តាមគេហទំព័រ sms.era.gov.kh ឬអាចមកបំពេញពាក្យសុំប្រឡងតាម Online នៅសាលាភូមិន្ទរដ្ឋបាល
- សាលានឹងទទួលឯកសារចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ១៧ម៉៣០នាទី ជាពេលផុតកំណត់
- សូមភ្ជាប់មកជាមួយនូវរូបថតថ្មី ៤x៦ ចំនួន៤សន្លឹក(ផ្ទៃខាងក្រោយពណ៌ស) និងឯកសារច្បាប់ដើមរួមមាន៖ សំបុត្រកំណើត, អត្តសញ្ញាណបណ្ណ, សញ្ញាបត្រ(ចាប់ពីបរិញ្ញាបត្រឡើងទៅ), ប្រកាសតែងតាំងស៊ប់ (សម្រាប់មន្ត្រីរាជការ) រួមទាំងច្បាប់ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម(បញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)
- ការប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ រីឯកាលបរិច្ឆេទជាក់ស្តែង នឹងត្រូវប្រកាសបិទផ្សាយជូននៅពេលក្រោយ និងផ្សព្វផ្សាយលើគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល
- មុនពេលប្រឡង សាលានឹងមានបើកថ្នាក់រៀនត្រៀមសម្រាប់ការប្រឡងប្រជែងនេះផងដែរ ហើយការចុះឈ្មោះនឹងចាប់ផ្តើមពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩។ កាលបរិច្ឆេទនៃការចូលរៀនថ្នាក់ត្រៀមនឹងប្រព្រឹត្តទៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១៩ ។

<u>បញ្ជាក់៖</u>

- ការដាក់ពាក្យសុំសិទ្ធិប្រឡងតម្លៃ ៦០.០០០៛(ហុកសិបពាន់រៀលគត់)។

ចំពោះព័ត៌មានលំអិតផ្សេងៗទៀត សូមពិនិត្យមើលបន្ថែមតាមរយៈគេហទំព័រសាលា www.era.gov.kh ទំនាក់ទំនងតាមលេខទូរស័ព្ទ រៀងរាល់ម៉ោងធ្វើការដូចខាងក្រោម៖

លោក ហាស់ ស៊ីហ្វា ៖ ០៨៩ ៥៥ ៣១ ៥៥ លោក ហ្វូរ ហេងលី ៖ ០១៥ ៩៤ ៤២ ៧៧

ថ្ងៃអង្គារ ៨រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩
**សាលាភូមិន្ទរដ្ឋបាល**

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាភ្លើកជូឡុង (៥៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : 023 62 22 266
អ៊ីម៉ែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh